# កិច្ចព្រមព្រៀង

រវាង

រាជរដ្ឋាភិបាលកម្ពុជា

និង

រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ស្តីពី

កិច្ចសហប្រតិបត្តិការបច្ចេកទេស

ឆ្នាំ ២០១៧ - ២០១៨

# រាជរដ្ឋាភិបាលកម្ពុជា
# និង
# រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីនៃទំនាក់ទំនងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងបំណងពង្រឹង និងរឹតចំណងទំនាក់ទំនងមិត្តភាព តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងស្មារតីនៃភាពជាដៃគូ

ដោយយល់ថា ការថែរក្សាទំនាក់ទំនងនេះគឺជាមូលដ្ឋានគ្រឹះនៃកិច្ចព្រមព្រៀងនេះ

ក្នុងគោលបំណងរួមចំណែកការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

យោងរបាយការណ៍សង្ខេប ស្តីពីកិច្ចចរចាអន្តររដ្ឋាភិបាល នាថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៧ នៅរាជធានីភ្នំពេញ

បានព្រមព្រៀងដូចខាងក្រោម ÷

**មាត្រា ១**

១- អនុលោមតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលត្រូវបានចុះហត្ថលេខានាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គម្រោងដូចមានចែងខាងក្រោម ត្រូវបានទទួលការគាំទ្រ ÷

ក- កម្មវិធីស្តីពីការកែទម្រង់វិមជ្ឈការ និងរដ្ឋបាល

ខ- កម្មវិធីស្តីពីការគាំពារសុខភាពសង្គម

គ- កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន- ដំណាក់កាលទី ៤

ឃ- កម្មវិធីពិពិធកម្មសេដ្ឋកិច្ចមូលដ្ឋាន និងការបង្កើតការងារ

ង- កម្មវិធីសមាហរណកម្មកម្ពុជាក្នុងពាណិជ្ជកម្មអាស៊ានប្រកបដោយចីរភាព ដោយផ្តោតលើប្រព័ន្ធផលិតកម្មជនបទ និង

ច- មូលនិធិសម្រាប់ការសិក្សា និងអ្នកជំនាញ

ប្រសិនបើពិនិត្យឃើញថា គម្រោងទាំងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គាំទ្រ ។

២- សម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសរុបរបស់ខ្លួន ចំនួន ២០.៨០០.០០០ អឺរ៉ូ (ម្ភៃលានប្រាំបីរយពាន់អឺរ៉ូ) ក្រោមទម្រង់ជាការផ្តល់បុគ្គលិក, ធាតុចូល និងការផ្តល់ហិរញ្ញប្បទានសមស្រប ។ Deutsche Gesellchaft für Internationale Zusammenarbeit (GIZ) ទទួលបន្ទុកអនុវត្តគម្រោងដែលមានចែងក្នុងកថាខណ្ឌ ១.ក ដល់ ១.ច ខាងលើ ។

ABC

៣-	រាជរដ្ឋាភិបាលកម្ពុជា ត្រូវធានាថាកម្មវិធីទាំងអស់ដូចមានចែងក្នុងកថាខណ្ឌ ១ មានខ្ទង់ថវិកាផ្ទាល់ ដើម្បីធានាភាពរលូនក្នុងការអនុវត្តហើយស្ថាប័នទទួលបន្ទុកអនុវត្តផ្តល់ការគាំទ្រចាំបាច់សម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ។

៤-	ការសន្យាសម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ និងការសន្យាផ្តល់ហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសដែលមានចែងនៅក្នុងកថាខណ្ឌ ២ ខាងលើ នឹងត្រូវអស់សុពលភាពដោយគ្មានការជំនួសអ្វីទាំងអស់ ប្រសិនបើកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ មិនត្រូវបានអនុវត្តក្នុងរយៈពេល ៤ ឆ្នាំ បន្ទាប់ពីឆ្នាំដែលការសន្យាបានប្រកាសឡើង ។ កាលបរិច្ឆេទផុតសុពលភាពនៃការសន្យាដែលប្រកាសឡើងក្នុងឆ្នាំនេះ គឺថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៧ ។ ក្នុងរយៈពេលសុពលភាពនេះ ប្រសិនបើកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ត្រូវអនុវត្តបានត្រឹមតែមួយផ្នែកនៃការសន្យា ការលុបចោល នឹងត្រូវអនុវត្តចំពោះធនធានដែលនៅសេសសល់ក្រៅពីកិច្ចព្រមព្រៀងទាំងនេះ ។

## មាត្រា ២

ខ្លឹមសារលម្អិតនៃគម្រោងដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ និងការផ្តល់ហិរញ្ញប្បទានព្រមទាំងកាតព្វកិច្ចនានា នឹងត្រូវចែងក្នុងកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទានដោយឡែកដែលនឹងត្រូវកំណត់ដោយស្ថាប័នទទួលបន្ទុកអនុវត្ត ដូចមានចែងក្នុងមាត្រា ១.២ និង ១.៣ នៃកិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងនេះ ត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ និងបទប្បញ្ញត្តិនានារបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

## មាត្រា ៣

១-	រាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកបង់ពន្ធលើសម្ភារបរិក្ខារ, យានយន្ត និងគ្រឿងបន្លាស់នាំចូលសម្រាប់អនុវត្តគម្រោងដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ និងត្រូវចំណាយជំនួសឱ្យរដ្ឋាភិបាលសាធារណរដ្ឋសហពន្ធ័អាល្លឺម៉ង់ លើអាជ្ញាប័ណ្ណ, ពន្ធគយ, ថ្លៃឈ្នួលចូលចត, ពន្ធនាំចូល, ពន្ធនាំចេញ និងថ្លៃសេវាសាធារណៈដទៃទៀត រួមទាំងថ្លៃឈ្នួលឃ្លាំង ហើយត្រូវធានាថាការបំពេញបែបបទគយត្រូវដំណើរការដោយគ្មានការយឺតយ៉ាវ ។

២-	រាជរដ្ឋាភិបាលកម្ពុជា ត្រូវបង់ពន្ធ និងអាករផ្ទាល់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជំនួសឱ្យភ្នាក់ងារអនុវត្តគម្រោង ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដូចមានចែងនៅក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ។

៣-	តបតាមសំណើរបស់ភ្នាក់ងារអនុវត្តគម្រោងរបស់អាល្លឺម៉ង់ រាជរដ្ឋាភិបាលកម្ពុជានឹងបង់អាករលើតម្លៃបន្ថែម ឬពន្ធមិនចំពោះផ្សេងៗលើសម្ភារបរិក្ខារ និងសេវាកម្មដែលធ្វើលទ្ធកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា នឹងត្រូវបង់ពន្ធលើការប្រើប្រាស់ជាក់លាក់ណាមួយ តបតាមសំណើរបស់ភ្នាក់ងារអនុវត្តគម្រោងរបស់អាល្លឺម៉ង់ ។

PBC

៤-	ដើម្បីជំរុញការបន្តគាំទ្ររបស់រដ្ឋាភិបាលទាំងពីរ ចំពោះគម្រោងដែលបានសន្យាមួយ ឬច្រើន កិច្ចព្រមព្រៀងនេះ នឹងមានវិសាលភាពគ្រប់ដណ្តប់ដូចគ្នាចំពោះគម្រោងទាំងអស់ដែលមានចែងក្នុងមាត្រា ១.១ ខាងលើ ក៏ដូចជាចំពោះវិធានការសម្រាប់បន្តអនុវត្តគម្រោងដែលមានឈ្មោះដូចគ្នា ។ ការសន្យាផ្តល់ការគាំទ្ររបស់រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ទៅលើវិធានការសម្រាប់បន្តអនុវត្តគម្រោង ដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវចូលជាធរមានតាមរយៈទំនាក់ទំនងផ្លូវការពីរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។

**មាត្រា ៤**

ក្នុងទិដ្ឋភាពដទៃទៀត ខ្លឹមសារទាំងឡាយនៃកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលបានចុះហត្ថលេខានាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលមានចែងក្នុងមាត្រា ១.១ ខាងលើ នឹងត្រូវយកមកអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៥**

១-	កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

២-	កិច្ចព្រមព្រៀងនេះ អាចនឹងត្រូវបញ្ចប់មុនកាលកំណត់បាន ។ ភាគីម្ខាងនៃកិច្ចព្រមព្រៀងអាចស្នើសុំបញ្ចប់ជាលាយលក្ខណ៍អក្សរតាមរយៈយន្តការការទូតក្នុងពេលណាមួយ ។ ការបញ្ចប់កិច្ចព្រមព្រៀងនឹងត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសំណើជាលាយលក្ខណ៍អក្សរនោះត្រូវបានទទួលដោយភាគីម្ខាងទៀតនៃកិច្ចព្រមព្រៀង ។

៣-	ភាគីនៃកិច្ចព្រមព្រៀង អាចស្នើសុំធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះបាន ។

៤-	រាល់វិវាទពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តកិច្ចព្រមព្រៀងនេះនឹងត្រូវដោះស្រាយដោយសន្តិវិធីរវាងភាគីទាំងពីរតាមរយៈការពិភាក្សា ឬការចរចា ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៧ ជាភាសាខ្មែរ, ភាសាអាល្លឺម៉ង់ និងភាសាអង់គ្លេស ។ អត្ថបទទាំង ៣ ភាសានេះ មានតម្លៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នារវាងអត្ថបទភាសាអាល្លឺម៉ង់ និង ភាសាខ្មែរ នោះ អត្ថបទជាភាសាអង់គ្លេស នឹងត្រូវទុកជាបានការ ។

| | |
|---|---|
| **តំណាង** | **តំណាង** |
| **រាជរដ្ឋាភិបាលកម្ពុជា** | **រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់** |
| Sean B. Chin | Ingo Karsten |
| **ជិន ប៊ុនសឿន** | **Ingo Karsten** |
| **ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស** | **ឯកអគ្គរដ្ឋទូត** |
| **អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** | **សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា** |

CBC

IK